**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជជ
ភាគីដាក់ឯកសារ៖ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី
ដាក់ជូន៖ **អង្គជំនុំជម្រះសាលាដំបូង**
ភាសាដើម៖ បារាំង(បកប្រែភាសាខ្មែរ)
កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-Sep-2011, 15:12
CMS/CFO: Kauv Keoratanak

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស៖ **សាធារណៈ/Public**
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

# ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើរបស់អៀងសារីសុំឲ្យ អង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានក្នុងដីកាដំណោះស្រាយ

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ពេជ អង្គ
មេធាវី Elisabeth SIMONNEAU-FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

មេធាវី ជេត វណ្ណលី
មេធាវី គីម ម៉េងឃី
មេធាវី ហុង គីមសួន
មេធាវី ឡោ ជុនធី
មេធាវី ម៉ុច សុវណ្ណារី
មេធាវី ស៊ិន សុវ៉ន
មេធាវី សំ សុគង់
មេធាវី វ៉េន ពៅ
មេធាវី ទី ស្រ៊ីនណា
មេធាវី Emmanuel ALTIT
មេធាវី Pascal AUBOIN
មេធាវី Olivier BAHOUGNE
មេធាវី Patrick BAUDOIN
មេធាវី Evelyne BOILEAU-BRANDOMIR
មេធាវី Philippe CANONNE

**ដាក់ជូន៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម ធូ មណី

**ចម្លងជូន៖**

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង
លោក Andrew CAYLEY
លោក យ៉េត ចរិយា
លោក William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន
អៀង សារី

មេធាវី Annie DELAHAIE
មេធាវី Laure DESFORGES
មេធាវី Ferdinand DJAMMEN NZEPA
មេធាវី Nicole DUMAS
មេធាវី Isabelle DURAND
មេធាវី Françoise GAUTRY
មេធាវី Marie GUIRAUD
មេធាវី Emmanuel JACOMY
មេធាវី Martine JACQUIN
មេធាវី Daniel LOSQ
មេធាវី Christine MARTINEAU
មេធាវី Madhev MOHAN
មេធាវី Silke STUDZINSKY
មេធាវី Barnabé NEKUIE
មេធាវី Lyma Thuy NGUYEN
មេធាវី Elisabeth RABESANDRATANA
មេធាវី Julien RIVET
មេធាវី Fabienne TRUSSES NAPROUS
មេធាវី Nushin SARKARATI
មេធាវី Philippine SUTZ

អៀង ធីរិទ្ធ
នួន ជា

**សហមេធាវីការពារក្តី៖**
មេធាវី សុន អរុណ
មេធាវី Michiel PESTMAN
មេធាវី Victor KOPPE
មេធាវី អាង ឧត្តម
មេធាវី Michael G. KARNAVAS
មេធាវី ផាត់ ពៅស៊ាង
មេធាវី Diana Ellis
មេធាវី ស សូវាន
មេធាវី Jacques VERGES

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ សហចៅក្រមស៊ើបអង្កេតបានចេញ ដីកាដំណោះស្រាយ ដែលមានឧបសម្ព័ន្ធឯកសារយោងនានា ដោយមានទាំងរបាយការណ៍ទាំងឡាយស្តីអំពីការកំណត់អត្តសញ្ញាណទីកន្លែង។ ក្នុងចំណោមនោះ ក៏មានឯកសារយោងចង្អុលបង្ហាញអំពីរូបថត និងសភាពនៃទីកន្លែង ដែលជាកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្ម ដូចមានចែងនៅក្នុងដីកាដំណោះស្រាយខាងលើ។

2. កាលពីថ្ងៃទី២៧ ខែមិថុនា ដល់ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១១ នៅក្នុងអំឡុងពេលនៃសវនាការបឋម អង្គជំនុំជម្រះបានកំណត់ប្រធានបទចំនួនបួនដំបូង ដែលនឹងត្រូវយកមកពិភាក្សាដេញដោលនៅក្នុងសវនាការលើអង្គសេចក្តីនាពេលក្រោយ។

3. នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ មេធាវីការពារក្តីរបស់លោកអៀង សារី បានដាក់នូវសេចក្តីស្នើសុំដល់អង្គជំនុំជម្រះ ឲ្យក្នុងការចុះពិនិត្យដល់ទីកន្លែងនៃឧក្រិដ្ឋកម្មនានាដែលមានក្នុងដីកាដំណោះស្រាយ។[1]

4. នៅក្នុងសំណើរបស់ខ្លួន ក្រុមមេធាវីការពារក្តី លោកអៀង សារី មានបំណង់ចង់បង្ហាញថា ការចុះពិនិត្យដល់ទីកន្លែងបែបនេះ នឹងផ្តល់លទ្ធភាពឲ្យអង្គជំនុំជម្រះអាចសង្កេតមើលភូមិសាស្រ្ត សភាពនៃទីតាំង និងទំនាក់ទំនងជារូបវ័ន្តរវាងទីតាំងនានា ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ។

5. ក្រុមមេធាវីការពារក្តី បានលើកឡើងបន្ថែមទៀតថា ការចុះពិនិត្យទីកន្លែងនេះ ត្រូវតែចាប់អនុវត្តឲ្យបានមុនការចាប់ផ្តើមនៃសវនាការលើអង្គសេចក្តី។

6. សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី សូមជំទាស់នឹងសំណើនេះ និងសូមបង្ហាញនូវទឡ្ហីករណ៍ដើម្បីគាំទ្រការជំទាស់របស់ខ្លួនដូចខាងក្រោមនេះ។

---

[1] សំណើរបស់អៀងសារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែង ០០២/១៩-០៩-២០០៧-អវតក/អជសដ E113 ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១

ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើររបស់អៀងសារីសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានក្នុងដីកាដំណោះស្រាយ

## II. ការពិភាក្សា

7. ដើម្បីឲ្យអង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់ខ្លួន នៅក្នុងរឿងនៃការចុះពិនិត្យដល់ទីកន្លែងឧក្រិដ្ឋកម្ម ភាគីការពារក្តី អៀង សារីបានផ្អែកដោយខុសតែម្តងទៅលើអំណានជាពិសេស នៃវិធាន៩៣ នៃវិធានផ្ទៃក្នុង «វិធានផ្ទៃក្នុង» ហើយក៏ផ្អែកដោយមានការភ័ន្តច្រឡំស្ទើរតែទាំងស្រុង លើការបកស្រាយយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(TPIY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា (TPIR) ផងដែរ។

8. ជាការពិតចំនុចនេះ និងជាចម្បង សហមេធាវីសូមអះអាងថាសំណើរបស់លោក អៀង សារី មិនមានមូលដ្ឋានច្បាប់ច្បាស់លាស់នៅក្នុងប្រព័ន្ធរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា («អវតក»)។

9. ជាកិច្ចបន្ទាប់បន្សំ សហមេធាវីក៏សូមបង្ហាញថា សំណើរបៀបនេះវាក៏មិនសមស្រប និងពុំជួនកាលដូចតាមបណ្តាយុត្តិសាស្ត្រដែលភាគីការពារក្តី អៀង សារី លើកយកមកសម្អាងនោះដែរ។

### a. ការឈរលើកង្វះមូលដ្ឋានច្បាប់របស់សំណើដែលដាក់ដោយភាគីការពារក្តី អៀង សារី

10. នៅក្នុងសំណើរបស់ខ្លួនផ្ទាល់នេះ ភាគីការពារក្តី អៀង សារី បានទទួលថា ថា មិនមានបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងអ.វ.ត.កណាមួយ ដែលបានចែងយ៉ាងច្បាស់លាស់អំពី គោលការណ៍នៃការចុះពិនិត្យដល់ទីកន្លែងដោយអង្គជំនុំជម្រះនោះទេ។

11. ផ្ទុយទៅវិញ ភាគីការពារក្តី អៀង សារី ដោយប៉ាន់ស្មានថាបានរកឃើញនូវល្បិចដោះខ្លួនតាមរយៈភាពចន្លោះប្រហោងផ្នែកច្បាប់នោះ បានលើកឡើងថាការចុះពិនិត្យដល់ទីកន្លែងជាអំណាចមួយដែលមាននៅគ្រប់ស្ថាប័នយុត្តាធិការទាំងអស់។

12. គាត់ក៏បានលើកឡើងអំពីឧទាហរណ៍នៃ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (TPIY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា(TPIR)ដែលបានពង្រីកនូវការអនុវត្ត

ជាក់ស្តែងនៃការចុះពិនិត្យដល់ទីកន្លែង បើទោះជាគ្មាននូវអត្ថបទច្បាប់ដែលចែងច្បាស់អំពីវិធានការជាក់លាក់ទាំងក្នុងវិធាននីតិវិធី និងវិធាននៃភស្តុតាងរបស់ពួកគេក៏ដោយ។

13. ក៏ប៉ុន្តែ បើពិនិត្យឲ្យជាក់លាក់ទៅបណ្តាឧទាហរណ៍ដែលលើកឡើងដោយពួកគេខ្លួនឯងផ្ទាល់នោះ គឺមិនគ្រប់គ្រាន់ ពីព្រោះថា យ៉ាងហោចណាស់ក៏ស្ថាប័នយុត្តាធិការទាំងពីរខាងលើនេះ បានបង្កើតនូវមូលដ្ឋានច្បាប់នៃវិធានការទាំងនេះនៅក្នុងបទប្បញ្ញត្តិនៃមាត្រា៤ និងនៃមាត្រា៥៤ នៃវិធាននីតិវិធីរៀងៗខ្លួន ដែរ។[2]

14. ដូច្នេះវិធានការការលើកឡើងបែបនេះ មិនអាចជាករណីស៊ីគ្នាទៅនឹងប្រព័ន្ធរបស់អ.វ.ត.កបានឡើយ ពីព្រោះវិធាន៩៣ នៃវិធានផ្ទៃក្នុង មិនមានសភាពស្រដៀងគ្នាជាមួយនឹងអត្ថបទច្បាប់ដែលជាមូលដ្ឋានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (TPIY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា (TPIR) ក្នុងការបង្គាប់បញ្ជាឲ្យចុះពិនិត្យដល់ទីកន្លែងនោះឡើយ។

អវត្តមាននៃភាពស្រដៀងគ្នានេះមានសភាពច្បាស់ក្រឡែតតែម្តងនៅក្នុងប្រព័ន្ធអ.វ.ត.ក ដែលមានចែងយ៉ាងជាក់លាក់អំពី ស្ថាប័នសហចៅក្រមស៊ើបអង្កេត។ ស្ថាប័នចៅក្រមស៊ើបអង្កេតគឺមិនមានចែងតែម្តងនៅក្នុងវិធានរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(TPIY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិ សម្រាប់ប្រទេសរ្វាន់ដា (TPIR) ។

15. តាមពិត វិធាន៩៣ត្រូវអានដូចខាងក្រោមនេះថា:

*«១.ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ការស៊ើបសួរថ្មីជាការចាំបាច់ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យធ្វើការស៊ើបសួរបន្ថែមបានគ្រប់ពេលវេលា។ សាលក្រមមុនអង្គសេចក្តីនេះ ត្រូវកំណត់បង្ហាញអំពី ចៅក្រមមួយរូប ឬច្រើនរូប ដែលត្រូវជាអ្នកដឹកនាំការស៊ើបសួរថ្មីនេះ។*

*២. ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែម ក៏ត្រូវស្ថិតនៅក្រោមល័ក្ខខ័ណ្ឌដូចគ្នាទៅនឹងសហចៅក្រមស៊ើបអង្កេតដែរ ហើយអាច៖*

*ក. ចុះទៅដល់ទីកន្លែងណាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច នៃយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា*

[2] សូមមើល កថាខណ្ឌ ៤ សំណើរបស់អៀងសារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែង ០០២/១៩-០៩-២០០៧-អវតក/អជសង E113 ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១១
ចម្លើយតបរបស់សហមេធាវីទាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើរបស់អៀងសារីសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានក្នុងដីកាដំណោះស្រាយ

*ខ. ស្ដាប់ចម្លើយសាក្សី*

*គ. ដឹកនាំការឆែកឆេរ*

*ឃ. ចាប់យកវត្ថុតាង ឬ*

*ង. បង្គាប់ឲ្យធ្វើកោសលវិច័យ.*

*៣. ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រមអាចចេញដីកាចាត់ឲ្យសួរជំនួសទៅមន្ត្រីនគរបាលយុត្តិធម៌បានដែរ។»*

16. វិធាននេះត្រូវបានវាយតម្លៃនៅក្នុងក្របខ័ណ្ឌនៃប្រព័ន្ធរូម៉ាំងអាល្លឺម៉ង់ដែលកំណត់នីតិវិធីត្រូវអនុវត្តនៅចំពោះមុខអ.វ.ត.។

17. ក្នុងករណីដូចគ្នា វិធាននេះក៏មានសភាពស្រដៀងគ្នាទៅនឹងបញ្ញត្តិដែលចែងនៅក្នុង ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាផងដែរ។[3]

18. អង្គជំនុំជម្រះអង្គសេចក្ដី ទទួលសំណុំរឿងតាមរយៈដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត(វិធាន ៦៩(២)(ក) និង វិធាន៧៩)។

19. ជាក់ស្ដែង បេសកកម្មស៊ើបអង្កេតដ៏ចំបងនេះបានផ្ដល់យ៉ាងច្បាស់ឲ្យសហចៅក្រមស៊ើបអង្កេត ហើយគឺដើម្បីអនុវត្តកិច្ចការនេះ សហចៅក្រមស៊ើបអង្កេតមានអំនាចដ៏ពេញលេញរបស់ខ្លួន ដែលបានផ្ដល់ដោយវិធាន៥៥ វិធាន៦១ និងវិធាន៦២ នៃវិធានផ្ទៃក្នុង។

20. អាស្រ័យទៅលើអំនាចផ្ដល់ឲ្យនេះហើយ ដែលសហចៅក្រមស៊ើបអង្កេតខាងលើបានបង្កើតនៅក្នុងសំនុំរឿងនេះនូវឧបសម្ព័ន្ធ ឯកសារយោងជាច្រើន ដែលរួមមានដូចជា ទិន្នន័យភូមិសាស្ត្រ និង ស្ថានភាពទីតាំងនៃទីតាំងនានាដែលបានចង្អុលបង្ហាញនៅក្នុងដីកាដំណោះស្រាយរបស់ខ្លួនបណ្ដាឧបសម្ព័ន្ធឯកសារយោងទាំងនេះមិនបានក្លាយកម្មវត្ថុនៃជំទាស់មួយណាសោះ ហើយក៏មិនទាន់ក្លាយជាកម្មវត្ថុនៃការដេញដោលអំពីភាគីនៅក្នុងដំណាក់កាលនៃនីតិវិធីតាមន័យនៃការស៊ើបអង្កត។ ផ្ទុយទៅវិញ ភាគីនីមួយៗមានលទ្ធភាពស្នើសុំកិច្ចស៊ើបសួរខ្លះៗ និងអាចស្នើសុំជាអាទិ៍ដូចជា កិច្ចស៊ើបសួរមួយ ឬច្រើនដល់ទីកន្លែងដោយយោងតាមការអនុវត្តវិធាន ៥៥.១០ នៃវិធានផ្ទៃក្នុង។

---

[3] សូមមើលមាត្រា៣៣៩ស្ដីអំពីពត៌មានបន្ថែមដែលបង្គាប់ដោយតុលាការនៃក្រមព្រហ្មទណ្ឌកម្ពុជា
ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីចំពោះសំណើររបស់អៀងសារីសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានក្នុងដីកាដំណោះស្រាយ

21. នៅក្នុងដំណាក់កាលនៃការស៊ើបអង្កេត ភាគីនីមួយៗសុទ្ធតែមានលទ្ធភាពស្នើសុំនូវកិច្ចស៊ើបសួរមួយចំនួន ហើយជាពិសេសគឺកិច្ចស៊ើបសួរមួយឬច្រើនទាក់ទងនឹងការចុះពិនិត្យដល់ទីកន្លែងដោយអនុលោមតាមវិធាន៥៥(១០)។

22. ដូច្នេះ សំនុំរឿងដែលបញ្ជូនទៅអង្គជំនុំជម្រះនោះមានគ្រប់នូវការស៊ើបអង្កេតនិងគ្រប់ពត៌មានចំបាច់នានាសម្រាប់ដំណាក់កាលជំនុំជម្រះលើអង្គសេចក្តី។

23. ជាវិបាក និងជាជំហានដំបូងចេញមកអំពីវិធាន៩៣ វាមានភាពឡូស៊ិកណាស់ដែលអង្គជំនុំជម្រះសាលាមិនមានអំណាចណាមួយដោយកំណត់ទុកជាមុននូវការបង្គាប់បញ្ជា ដែលថាខ្លួននឹងអនុវត្តដោយផ្ទាល់នូវវិធានការស៊ើបសួរបន្ថែមថ្មីនោះទេ។

24. ជាបន្ទាប់ទៀត អង្គជំនុំជម្រះនឹងអាចអនុវត្តអំនាចនេះបាន លុះត្រាណាតែក្នុងលក្ខខ័ណ្ឌទុកជាមុនថាខ្លួនអាចនឹងចាត់នូវវិធានការ**ការស៊ើបសួរថ្មីប្រសិនបើចាំបាច់។**

25. លើសពីនេះទៀត ជាដំបូងគេត្រូវតែគូសបញ្ជាក់ថាវាមាន ការស៊ើបអង្កេតដែលធ្វើហើយដោយសហចៅក្រមស៊ើបអង្កេត ហើយដែលមានកំណត់នៅក្នុងដីកាដំណោះស្រាយ ថានៅមិនទាន់គ្រប់គ្រាន់។ មានតែការពិភាក្សាដេញដោលតែមួយគត់ដែលអាចបង្ហាញថាមានភាពមិនគ្រប់គ្រាន់ណាមួយជាយថាហេតុ។

26. ជាចុងក្រោយ អំនាចរបស់អង្គជំនុំជម្រះក្នុងការអនុវត្តនូវវិធានការបែបនេះត្រូវបានកម្រិត យ៉ាងដាច់ខាតដោយត្រូវតែងតាំងចៅក្រមមួយរូប ឬច្រើនរូបរបស់ខ្លួនវិញ ។

27. នេះជាគោលការណ៍ដែលបានបញ្ញត្តិយ៉ាងច្បាស់ក្រឡែតដោយកថាខណ្ឌ១ នៃវិធាន៩៣។

28. នៅក្នុងករណីនេះ ភាគីការពារក្តី អៀង សារី មិនបានដាក់នូវភស្តុតាងបន្តិចទាល់តែសោះ ដើម្បីបង្ហាញអំពីភាពចាំបាច់ក្នុងការស៊ើបសួរជាថ្មី ដើម្បីបំពេញបន្ថែមលើការស៊ើបអង្កេតជាសារធាតុពីមុនដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត រហូតទាល់តែចៅក្រមស៊ើបអង្កេតទៀតសោតក៏បានចេញដីកាដំណោះស្រាយរបស់ខ្លួន កាល ពីថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ផងដែរ។

29. ជាវិបាក សហាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រថា វាមិនមានភាពស្រដៀងគ្នារវាងប្រព័ន្ធវិធានច្បាប់របស់អ.វ.ត.ក ជាមួយនិងបទប្បញ្ញត្តិរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(TPIY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា (TPIR) ដែលអនុវត្តការចុះពិនិត្យដល់ទីកន្លែងនោះឡើយ។

30. ដូចនេះ ជាការឥតប្រយោជន៍ទេដែលលោក អៀង សារីបានលើកយកវិធាន៨៣ មកធ្វើមូលដ្ឋានសម្អាងនៅក្នុងសំណើរបស់ខ្លួនក្នុងចុះទៅពិនិត្យដល់ទីកន្លែង។

**b. លក្ខណៈមិនជួនកាល និងមិនសមស្របរបស់សំណើរបស់លោក អៀង សារី ដោយយោងទៅលើយុត្តិសាស្ត្រដែលដែលបានដាក់មក**

31. លោក អៀង សារីបានបង្ហាញបន្ថែមទៀតថា ខ្លួនបានរកឃើញអំពីយុត្តិកម្មនៅក្នុងការអនុវត្តជាក់ស្តែងដោយយុត្តិសាស្ត្ររបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី(TPIY) និងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា (TPIR)។ យុត្តិសាស្ត្រនេះបានផ្តល់នូវគោលការណ៍មួយដែលអនុញ្ញាតឲ្យមានការចុះពិនិត្យដល់ទីកន្លែងរបស់អង្គជំនុំជម្រះ គឺធ្វើដើម្បីផលប្រយោជន៍នៃយុត្តិធម៌។

32. ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (TPIY) មានរឿងក្តីមួយចំនួនដែល អៀង សារីបានលើកឡើងដូចជា «ម៉ាកទីក (Martic)» «ការាតហ្សីក (karadzic)» និង «ពើរីស៊ិក (Perisic)»។ ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា(TPIR) មានរឿងក្តីមួយចំនួនដែល អៀង សារីបានលើកឡើងដូចជា«ណ្សាបូនីម៉ាណា (Nzabonimana)» «ការ៉េម៉េរ៉ា (karemera) និង ណើហ្សីរ៉ុមប៉ាត់(Ngirumpatse)» ព្រមទាំង «ហ្គាទីស (Gateste)»។

33. សហាមេធាវី យល់ស្របដែលថាការបំរើបំរាស់នូវការចុះពិនិត្យដល់ទីកន្លែងនោះ មិនចោទជាបញ្ហាដុំកំភួនប៉ុន្មាននោះទេ ។ ប៉ុន្តែបើពិនិត្យពិច័យឲ្យមែនទែននូវរាល់យុត្តិសាស្ត្រដែលលើកឡើងដោយភាគីអៀងសារី យើងឃើញថាការអនុម័តនូវវិធានការដែលចាត់ទុកថាចាំបាច់ត្រូវធ្វើទាំងនោះ គឺបន្ទាប់ពីមានការដេញដោលលើអង្គសេចក្តីប៉ុណ្ណោះ ។ វិធានការបែបនេះគឺមិនដែលអនុវត្តទាល់តែសោះនៅមុនពេលបើកការពិភាក្សាដេញដោល ដូចជាការចង់បានរបស់ភាគីការពារក្តីនៅក្នុងករណីនេះឡើយ។

34. ដូចនេះ ចំពោះរឿងក្ដី«ពេរីស៊ិក (Perisic)» ដែលបានលើកឡើងដោយ អៀង សារី គឺនៅថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៩ ដែលអង្គជំនុំជម្រះក៏បានកំណត់ ចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩ នូវការចុះពិនិត្យដល់ទីកន្លែងរបស់ខ្លួន។ សេចក្ដីសម្រេចនេះត្រូវបានអនុវត្តអស់រយៈពេលជាច្រើនខែបន្ទាប់ ពីថ្ងៃទី០២ ខែតុលា ឆ្នាំ២០០៨ ដែលចាប់ពីកាលបរិច្ឆេទនេះភាគីត្រូវដេញដោលលើការលើកទឡ្ហីករណ៍នៃភស្តុតាងរបស់ព្រះរាជអាជ្ញា[4]។

35. ជាមួយគ្នានេះដែរ ចំពោះរឿងក្ដីរបស់ «ការាតហ្សិក (karadzic)» សេចក្ដីសម្រេចដែលបង្គាប់បញ្ជាឲ្យមានការចុះពិនិត្យទីកន្លែងចេញនូវថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ ហើយវាក៏បានរៀបចំកម្មវិធីចុះនោះសម្រាប់ខែឧសភា ឆ្នាំ២០១១ ក្នុងខណៈពេលដែលកិច្ចពិភាក្សាបានចាប់ផ្ដើមតាំងពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០០៩[5]។

36. ប្រហាក់ប្រហែលនេះដែរ នៅក្នុងរឿងក្ដីរបស់ «ម៉ាកទីក (Martic)»៖សេចក្ដីសម្រេចកាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៦ បានបង្គាប់បញ្ជាឲ្យមានការចុះពិនិត្យទីកន្លែងកាលក្នុងរវាងថ្ងៃទី២៥ និង ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៦ ក្នុងខណៈពេលដែលរឿងក្ដីបានចាប់ផ្ដើមតាំងពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៥។ ហើយចំណែកឯព្រះរាជអាជ្ញា ក៏បានបញ្ចប់នៃការធ្វើកិច្ចបង្ហាញអំពីទឡ្ហីករណ៍នៃភស្តុតាង កាលពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៦[6]។

37. ឲ្យកាន់តែច្បាស់ម្ដងទៀត ករណីទាក់ទងជាមួយនឹងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា (TPIR) ដែលលោក អៀង សារីបានយោងមកធ្វើជាសម្អាងនៅក្នុងសំណើរបស់ខ្លួនដោយយកសេចក្ដីណែនាំអនុវត្តរបស់តុលាការនេះកាលពីខែឧសភា ឆ្នាំ២០១០ ដែលតាមពិត សេចក្ដីណែនាំទាំងនេះ

[4] មើលសន្និសីទការសែតរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី «អង្គបុរេជំនុំជម្រះចុះពិនិត្យដល់កន្លែងគីហ្សាក្រេប (Zagreb) សារាជីវូ (Sarajevo) និងស្រ៊ីប្រឺនីកា (Srebrenica) នៅក្នុងករណីរបស់មរម៉ីលលោ ពេរីស៊ិក (Momeilo perisic)» កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌចុងក្រោយ។

[5] មើលសន្និសីទការសែតរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី «ក្នុងករណីរបស់ ការាតហ្សិក (karadzic)អង្គបុរេជំនុំជម្រះចុះពិនិត្យដល់កន្លែង» កាលពីថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១១ កថាខណ្ឌចុងក្រោយ។

[6] មើលសន្និសីទការសែតរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី «ក្នុងករណីរបស់ មីលាន ម៉ាកទីក ( Milan Martic)អង្គបុរេជំនុំជម្រះចុះពិនិត្យដល់កន្លែងនៃបទឧក្រិដ្ឋដែលចោទប្រកាន់នៅក្នុង ក្រូអាត្ហា(Croatia) និងបូសនីយ៉ា(Bosnia) និង ហ៊ើហ្សីហ្គូវីណា (Herzegovina)» កាលពីថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៦ កថាខណ្ឌចុងក្រោយ។

បានចង្អុលបង្ហាញយ៉ាងច្បាស់ណាស់ថា វិធានការដែលទាក់ទងនឹងការចុះពិនិត្យដល់ទីកន្លែងដោយ អង្គជំនុំជម្រះ នឹងកំណត់ ឬនឹងអាចកំណត់បានល្អិតណាតែបញ្ចប់កិច្ចពិភាក្សាដេញដោលតែប៉ុណ្ណោះ។ គោលការណ៍នេះ អាចឃើញបានយ៉ាងច្បាស់តាមរយៈការអនុវត្តនៅក្នុងរឿងក្តី «ណ្សាបូនីម៉ាណា (Nzabonimana) »។ ការចុះពិនិត្យដល់ទីកន្លែងត្រូវបានចាប់ផ្តើមរវាងថ្ងៃទី០៥ និងថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១១ ក្នុងខណៈពេលដែលកិច្ចពិភាក្សាដេញដោលចុងបញ្ចប់របស់ភាគី ត្រូវធ្វើនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១ គឺក្នុងរយៈពេលពីរខែមុនចាប់ផ្តើមចុះពិនិត្យដល់ទីកន្លែង[7]។

38. ដូចគ្នានេះផងដែរ នៅក្នុងសំនុំរឿង "Karemera និង Ngirumpaste" ការចុះពិនិត្យត្រូវបានកំណត់នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១០ នោះគឺបន្ទាប់អំពីសេចក្តីសន្និដ្ឋានបញ្ចប់របស់ភាគី[8]។

39. ចុងបញ្ចប់នៅក្នុងសំនុំរឿង "Gatete" ដែលត្រូវបានលើកឡើងដោយភាគីអៀងសារីផងដែរនោះ ភាគីការពារក្តីនៃសំនុំរឿងនោះបានបញ្ចប់ការបង្ហាញនូវទស្សីករណ៍នានាតាំងអំពីថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១០ ហើយគឺនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១០ ដែលអង្គជំនុំជម្រះបានបង្គាប់នូវការពិនិត្យដល់ទីកន្លែង ។[9]

40. ជារួម នៅគ្រប់ករណីដែលបានលើកឡើងនោះ គឺមាននៅក្នុងអំឡុងពេលនៃការដេញដោលអង្គសេចក្តីទេ ដែលភាគីបានតតាំងគ្នាជាមុននៅចំពោះអង្គជំនុំជម្រះ ដែលអាចអនុញ្ញាតិឲ្យអង្គជំនុំជម្រះធ្វើការវិនិច្ឆ័យខ្លួនត្រូវឬមិនត្រូវបង្គាប់ឲ្យមានការចុះពិនិត្យដល់ទីកន្លែងនោះ ។

41. ហេតុដូច្នេះ ទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ្វាន់ដា មិនបានបង្គាប់ចំណាត់ការចុះពិនិត្យដល់កន្លែងមុនការបើកនូវការដេញដោលនោះឡើយ។

42. ជាវិបាក ភាគីការពារក្តីអៀងសារីមិនអាចប្រើប្រាស់នូវយុត្តិសាស្ត្រដែលខ្លួនបានលើកសំអាងនោះ មកធ្វើយុត្តិកម្មនៃសំណើសុំរបស់ខ្លួន ដែលពុំជួនកាលនិងមិនស្របជាមួយនឹងស្ថានភាពបច្ចុប្បន្ននៃនីតិវិធីតែម្តង។

---

[7] មើល «ព្រះរាជអាជ្ញា និង កាលិក ណ្សាបូនីម៉ាណា (Callixte Nzabonimana)» តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ្វាន់ដា-98-44D-T, ដីកាកំណត់កាលបរិច្ឆេទ វិធាន៥៤ នៃវិធាននីតិវិធី និងភស្តុតាង កាលពីថ្ងៃទី១២ ខែមេសា ឆ្នាំ២០១១។

[8] សូមមើលសំនុំរឿង «រដ្ឋអាជ្ញាតទល់នឹង Edouard KAREMERA និង Matthieu NGIRUMPATSE », ICTR-98-44T, សេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាដើម្បីផ្លាស់ប្តូរការគណនាពាក្យដែលរាប់នៅការបិទការដេញដោល"Decision on the Prosecution"s motion to vary the calculation of word count for the closing brief", ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០១១

[9] សូមមើលសំនុំរឿង « រដ្ឋអាជ្ញាតទល់នឹង Jean-Baptise GATETE », ICTR-2000-61T,
« សេចក្តីសម្រេចលើកន្លែងត្រូវចុះពិនិត្យនៅរ្វាន់ដា » ចុះថ្ងៃទី១៧ មិថុនា ឆ្នាំ២០១១
ចម្លើយតបរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះសំណើររបស់អៀងសារីសុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មដែលមានក្នុងដីកាដំណោះស្រាយ

## III. សន្និដ្ឋាន

43. ជាចម្បង សហាមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីសុំឲ្យច្រានចោលនូវសំណើសុំរបស់ភាគី អៀង សារីដោយសារគ្មានមូលដ្ឋានច្បាប់ច្បាស់លាស់។

44. ជាបន្ទាប់បន្សំ ស្នើសុំឲ្យអង្គជំនុំជម្រះប្រកាសថា មិនអាចទទួលយកបាននូវសំណើនោះដោយសារតែលក្ខណៈពុំជួនកាលសមស្របទៅនឹងស្ថានភាពបច្ចុប្បន្ននៃនីតិវិធី។

ធ្វើនៅភ្នំពេញថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១១

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ០៧ កញ្ញា ២០១១ | ពេជ អង្គ<br>**សហាមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី** | ភ្នំពេញ | |
| | Elisabeth SIMONNEAU-FORT<br>**សហាមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី** | ភ្នំពេញ | |
| | **ម៉ុច សុវណ្ណារី**<br>សហាមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | **គឹម ម៉េងឃី**<br>សហាមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |
| | **Barnabé NEUKIE**<br>សហាមេធាវីអន្តរជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី | ភ្នំពេញ | |